ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងកូវីដ-១៩ សម្រាប់ជុំទី៣ លើកទី២

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ហើយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានចាប់ផ្តើមដំណើរការអនុវត្តកម្មវិធីនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ មកដល់បច្ចុប្បន្នបានចំនួន ៣ ជុំ មាន ៦លើក រួចមកហើយ ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានកិត្តិយសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា គិតត្រឹមថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង ១៨:០០ ការបើកផ្តល់ជុំទី៣ លើកទី២ ត្រូវបានបញ្ចប់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

| | ចំនួនគ្រួសារ | | ចំនួនសមាជិក | កុមារអាយុពី 0-៥ ឆ្នាំ | មនុស្សវ័យចាស់អាយុពី ៦០ឆ្នាំ | ជនមានពិការភាព | គ្រួសារដែលមានជំងឺអេដស៍ | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|
| | ក្រក្រ១ | ក្រក្រ២ | | | | | | |
| ទីប្រជុំជនក្នុងរាជធានី | 1,871 | 2,511 | 19,208 | 1,172 | 3,013 | 2,469 | 6 | 1,577,724,000 |
| ទីប្រជុំជនក្រៅរាជធានី | 16,068 | 13,666 | 133,537 | 11,455 | 14,287 | 7,952 | 3 | 9,350,616,000 |
| ជនបទ | 244,734 | 403,149 | 2,554,508 | 228,393 | 302,130 | 49,942 | 1,961 | 111,086,600,000 |
| សរុបគ្រួសារដែលបានទទួលសេវាឧបត្ថម្ភ | 262,673 | 419,326 | 2,707,253 | 241,020 | 319,430 | 60,363 | 1,970 | 122,014,940,000 |
| | 681,999 | | | | | | | |

(មួយរយម្ភៃពីរប៊ីលាន ដប់បួនលាន ប្រាំបួនរយសែសិបពាន់រៀលគត់)

ទន្ទឹមនេះផងដែរ រាជរដ្ឋាភិបាលបានផ្តល់ការអន្តរាគមន៍ក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាជនក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ចាប់ពីថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ដោយបានចំណាយថវិការជួសរុបចំនួន ៦៧៧,៥១៦,៧៣៦,០០០.០០៛ (ប្រាំមួយរយចិត សិបប្រាំពីរប៊ីលាន ប្រាំរយដប់ប្រាំមួយលាន ប្រាំពីររយសាមសិបប្រាំមួយពាន់រៀលគត់ **ស្មើនឹង ១៦៩.៣៨ លានដុល្លារអាមេរិក។**

ព្រមជាមួយគ្នានេះផងដែរ សម្រាប់ការបើកផ្តល់ប្រាក់ឧបត្ថម្ភជុំទី៣ លើកទី៣ នឹងចាប់ផ្តើមពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២១ មានរយៈពេល ៣០ថ្ងៃ នឹងត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម៖

- ចំពោះគ្រួសារដែលបានផ្ទៀងផ្ទាត់នៅជុំទី១ ជុំទី២ និងជុំទី៣ លើកទី២ រួចហើយ សូមអញ្ជើញទៅបើកប្រាក់ឧបត្ថម្ភនៅតាមបញ្ជរវីងណាមួយ ដោយមិនតម្រូវឱ្យមកសាលាឃុំ សង្កាត់សារជាថ្មីទៀតទេ។
- ចំពោះគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានបណ្ណសមធម៌មានសុពលភាព ហើយមិនទាន់បានផ្ទៀងផ្ទាត់នៅក្នុងជុំទី១ ជុំទី២ និងជុំទី៣ លើកទី២ និងគ្រួសារក្រីក្រ ដែលទើបទទួលបានបណ្ណសមធម៌ថ្មី សូមអញ្ជើញទៅផ្ទៀងផ្ទាត់នៅសាលាឃុំ សង្កាត់ណាមួយ ដើម្បីទទួលបានការឧបត្ថម្ភសាច់ប្រាក់ក្នុងជុំទី៣ លើកទី៣ នេះ។
- ពេលទៅបើកប្រាក់ឧបត្ថម្ភជុំទី៣ លើកទី៣ នៅតាមបញ្ជរវីង តម្រូវឱ្យអ្នកទទួលផលត្រូវភ្ជាប់ទៅជាមួយនូវឯកសារពាក់ព័ន្ធដូចគ្នានឹងការបើកប្រាក់ឧបត្ថម្ភជុំទី១ ជុំទី២ និងជុំទី៣ លើកទី២ ពិសេសបណ្ណសមធម៌ដែលនៅមានសុពលភាព និងត្រូវចងចាំលេខកូដសម្ងាត់។
- ករណីភ្លេចលេខសម្ងាត់ សូមទំនាក់ទំនងអ្នកទទួលបន្ទុកកម្មវិធីនៅតាមឃុំ សង្កាត់ ឬមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ។
- ក្នុងករណីប្រជាពលរដ្ឋ ឬសាធារណជន ពិនិត្យឃើញភាពមិនប្រក្រតីណាមួយក្នុងការអនុវត្តកម្មវិធីនេះ សូមសាធារណជនធ្វើការទំនាក់ទំនងជាមួយអ្នកកាន់កម្មវិធីនៅតាមឃុំ សង្កាត់ ឬនៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬមន្ទីរផែនការ រាជធានី ខេត្តនីមួយៗ។

ជាថ្មីម្តងទៀត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋបាលរាជធានី ខេត្ត ដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការគាំទ្រ និងជំរុញការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ឱ្យដំណើរការទៅដោយរលូន និងទទួលបានការសាទរយ៉ាងខ្លាំងពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ពិសេសប្រជាជនក្រីក្រដែលជាក្រុមជនងាយរងគ្រោះ និងកំពុងប្រឈមយ៉ាងខ្លាំងពីឥទ្ធិពលនៃជំងឺកូវីដ-១៩ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងស្ថាប័នពាក់ព័ន្ធ ជាពិសេស គ្រួសារក្រីក្រ និងងាយរងគ្រោះ ទាំងអស់មេត្តាជ្រាប និងបន្តសហការអនុវត្ត ដើម្បីឱ្យកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ប្រព្រឹត្តទៅដោយរលូន និងទទួលបានជោគជ័យបន្តទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់ការអន្តរាគមន៍ជំនួយសង្គមដល់ប្រជាជន ពិសេស គ្រួសារក្រីក្រ និងងាយរងគ្រោះ ដោយមិនទុកប្រជាជនណាម្នាក់ចោល ហើយមិនមានការយកចិត្តទុកដាក់ពីរដ្ឋនោះឡើយ ។

ថ្ងៃព្រហស្បតិ៍ ១០ កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០